ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# ការប៉ាន់ស្មាន និងការព្យាករណ៍ចំនួន អ្នកផ្ទុកមេរោគអេដស៍នៅថ្នាក់ក្រោមជាតិ នៅប្រទេសកម្ពុជា ២០១៦-២០២០

១៥ ធ្នូ ឆ្នាំ ២០១៦

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ

ឧបត្ថម្ភ ដោយអង្គការ UNAIDS

# អារម្ភកថា

ប្រទេសកម្ពុជា បានរៀបចំធ្វើការប៉ាន់ស្មាននិងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍ប្រកបដោយជោគជ័យ ចំនួនបួនលើកហើយ គឺនៅឆ្នាំ ២០០០, ២០០៣, ២០០៧, និង ២០១១។ ការប៉ាន់ស្មាននិងព្យាករណ៍ នៃអេពីដេមិកនៃមេរោគអេដស៍នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានលក្ខណៈបច្ចេកទេស ទាមទារនូវការខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តរួមគ្នា ពីគ្រប់ភាគីដៃគូអភិវឌ្ឍន៍-រដ្ឋាភិបាល អង្គការសហប្រជាជាតិ អង្គការសុខភាពពិភពលោក សមាជិក-សមាជិកាក្រុមការងារបច្ចេកទេសនៃព័ត៌មានជាយុទ្ធសាស្ត្រ ក្រោមការដឹកនាំ តម្រង់ទិសនិងភាពជាម្ចាស់ពីក្រសួងសុខាភិបាល/មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។ ការប៉ាន់ស្មាន និងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍នៅថ្នាក់ក្រោមជាតិលើកនេះនឹងផ្តល់ព័ត៌មានថ្មីៗ អំពីការបាន់ស្មានចំនួនអ្នកផ្ទុកមេរោគអេដស៍ ចំនួនអ្នកឆ្លងថ្មីនៃមេរោគអេដស៍ និងចំនួនអ្នកស្លាប់ទាក់ទងនឹងមេរោគអេដស៍ ប្រចាំរាជធានី/ខេត្តនីមួយៗសម្រាប់ឆ្នាំ ២០១៦-២០២០។

ជាលទ្ធផល មានការថយចុះអត្រាឆ្លងរាលដាលនៃមេរោគអេដស៍ពីអត្រា ១,៧% នៅឆ្នាំ ១៩៩៨ មក ០,៦% នៅឆ្នាំ២០១៥ ក្នុងចំណោមមនុស្សពេញវ័យអាយុពី ១៥-៤៩ឆ្នាំ និងព្យាករណ៍ថា នឹងថយចុះមកត្រឹម ០,៥% នៅឆ្នាំ ២០២០។ ក្នុងគោលបំណងគាំទ្រគោលដៅ និងកម្មវត្ថុនៃផែនការយុទ្ធសាស្ត្រជាតិ នៃការបង្ការការឆ្លងរាលដាលមេរោគអេដស៍ និងការថែទាំព្យាបាលបន្តជំងឺអេដស៍និងជំងឺកាមរោគ ក្នុងវិស័យសុខាភិបាលនៅប្រទេសកម្ពុជា (ឆ្នាំ ២០១៦-២០២០) ឈានទៅសម្រេចគោលដៅ ៩០-៩០-៩០ នៅឆ្នាំ២០២០ កាត់បន្ថយអត្រាស្លាប់ទាក់ទងនឹងមេរោគអេដស៍ និងកាត់បន្ថយការឆ្លងថ្មីនៃមេរោគអេដស៍នៅឆ្នាំ២០២០ តាមរយៈការសម្រេចបាននូវកម្មវត្ថុចម្បងបីៈ ១) កាត់បន្ថយការឆ្លងថ្មីនៃមេរោគអេដស៍ឲ្យនៅតិចជា៤០០ ករណី/ឆ្នាំ នៅឆ្នាំ ២០២០; ២) កាត់បន្ថយការចម្លងមេរោគអេដស៍ពីម្តាយទៅកូនពី ៦% នៅឆ្នាំ ២០១៥ ឲ្យតិចជាង ៥% នៅឆ្នាំ ២០២០; និងកាត់បន្ថយអត្រាស្លាប់ទាក់ទងនឹងមេរោគអេដស៍ពី ១៧,៩ នាក់/១០០ ០០០ នៅឆ្នាំ២០១៥ ដល់ ១២/១០០ ០០០ នៅឆ្នាំ២០២០។ កម្មវិធីទាមទារឲ្យមានការប៉ាន់ស្មាននិងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍នៅថ្នាក់ក្រោមជាតិដែលមានភាពជាក់លាក់ ដើម្បីជួយណែនាំ និងផ្តល់ព័ត៌មានក្នុងការសម្រេចចិត្តសម្រាប់អនុវត្តកម្មវិធី និងតាមដានការឆ្លើយតបទៅនឹងមេរោគអេដស៍ទូទាំងប្រទេស ។

ក្រសួងសុខាភិបាល សូមលើកទឹកចិត្តឲ្យប្រើប្រាស់របាយការណ៍នៃការប៉ាន់ស្មាន និងព្យាករណ៍នេះ ដើម្បីជួយរៀបចំកម្មវិធី និងឆ្លើយតបទៅនឹងការរាលដាល់នៃមេរោគអេដស៍នៅប្រទេសកម្ពុជាឲ្យកាន់តែប្រសើរឡើង និងមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញថ្ងៃទី 05 ខែ 05 ឆ្នាំ ២០១៧

ជ. រដ្ឋមន្ត្រីក្រសួងសុខាភិបាល

រដ្ឋលេខាធិការ

សាស្ត្រាចារ្យ អេង_ហួត

# សេចក្តីថ្លែងអំណរគុណ

ឯកសារការប៉ាន់ស្មាន និងព្យាករណ៍នេះត្រូវបានចងក្រងឡើងតាមរយៈការខិតខំប្រឹងប្រែងចូលរួមយ៉ាងសកម្ម ពីសំណាក់ឯកឧត្តម លោក លោកស្រីដែលមានរាយនាមដូចខាងក្រោម ៖

| | |
|---|---|
| H.E. Dr. Mean Chhi Vun | Advisor to MoH |
| H.E. Dr. Tia Phalla | Vice-Chair of NAA |
| Dr. Ly Penh Sun | Director of NCHADS |
| Dr. Ouk Vichea | Deputy Director/NCHADS |
| Mr. Mam Sovatha | Deputy Director/NCHADS |
| Dr. Lan Van Seng | Deputy Director/NCHADS |
| Dr. Seng Sopheap | Chief of Technical Bureau/NCHADS |
| Dr. Samreth Sovannarith | Vice-Chief of Technical Bureau/NCHADS |
| Dr. Khol Vohith | Chief of Research Unit/NCHADS |
| Dr. Sau Sokun Mealiny | Research Officer at Research Unit/NCHADS |
| Dr. Ngauv Bora | Vice-Chief of Technical Bureau/NCHADS |
| Dr. Mun Phalkun | Chief of Surveillance Unit/NCHADS |
| Dr. Chann Navy | Vice-Chief of Surveillance Unit/NCHADS |
| Ms. Marie Ryan | Grant Management Consultant/NCHADS |
| Dr. Heng Sopheab | Deputy Director/NIPH |
| Dr. Lek Dysoley | Deputy Director/CNM |
| Ms. Marie-Odile Emond | Country Director/UNAIDS |
| Dr. Muhammad Saleem | Strategic Information Advisor/UNAIDS |
| Ms. Gesine Lieberknecht | UNAIDS |
| Dr. Laurent Ferradini | HIV/Hepatitis/STI Team Leader/WHO |
| Dr. Deng Serongkea | Technical Officer/WHO |
| Dr. Ahmed Saadani | US/CDC |
| Dr. Lori Newman | HIV Strategic Information Advisor/PEPFAR |
| Mr. Parag Jalan | CHAI |
| Dr. Siyan Yi | KHANA-CPHR |
| Dr. Chhim Srean | FHI360 |
| Dr. Heang Phyrun | PSK |
| Ms. Long Dianna | PSK |
| Dr. Wiwat Peerapatanapokin | International Expert Consultant, East-West Center Program, Hawai, USA |
| Dr. Khieu Kimlee | National Consultant |

# មាតិកា


អារម្ភកថា ........ i

សេចក្ដីថ្លែងអំណរគុណ ........ ii

មាតិកា ........ iii

បញ្ជីតារាងនិងរូបភាព ........ v

បញ្ជីពាក្យបំព្រួញ ........ vi

សេចក្ដីផ្ដើម ........ 1

សាវតារ ........ 1

សេចក្ដីសង្ខេបអំពីស្ថានភាពមេរោគអេដស៍ជំងឺអេដស៍/ ........ 2

ប្រភពទិន្នន័យសំខាន់ៗដែលប្រើសម្រាប់ប៉ាន់ស្មាន និងព្យាករណ៍ ........ 3

គោលបំណង ........ 5

វិធីសាស្រ្ត ........ 5

ធ្វើបច្ចុប្បន្នភាពការប៉ាន់ស្មាន និងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍នៅថ្នាក់ជាតិ ........ 5

*1. ធ្វើបច្ចុប្បន្នភាពការប៉ាន់ស្មានទំហំក្រុមប្រឈមមុខ ឥរិយាបថផ្លូវភេទ និងប្រេវ៉ាឡង់នៅក្នុង AEM ២០១៤ ........ 5*

*2.ការរៀបចំដំណើរការ AEM 4.1 និង SPECTRUM V5.4 ដោយប្រើឧបករណ៍ AEM-SPECTRUM Fitting Tool .. 6*

*3. AEM-Spectrum បន្ទាប់ពីរៀបចំដាក់ឲ្យដំណើរការ )calibration( ........ 6*

ការប៉ាន់ស្មាន និងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍ នៅថ្នាក់ក្រោមជាតិ ........ 8

*2. ការប៉ាន់ស្មានអាំងស៊ីដង់មេរោគអេដស៍នៅថ្នាក់ខេត្តក្នុងចំណោមស្ត្រី អាយុលើសពី ១៥ឆ្នាំ ........ 9*

*3. ការប៉ាន់ស្មានអាំងស៊ីដង់មេរោគអេដស៍ក្នុងចំណោមប្រុស អាយុ > ១៥ឆ្នាំ ........ 9*

*4. ការប្រើគំរូ AEM និង Spectrum សម្រាប់ប៉ាន់ស្មាន និងព្យាករណ៍នៅថ្នាក់ក្រោមជាតិ ........ 10*

លទ្ធផល ........ 12

ការប៉ាន់ស្មាន និងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍ថ្នាក់ជាតិ ........ 12

*1. ប្រេវ៉ាឡង់នៃមេរោគអេដស៍នៅថ្នាក់ជាតិ ........ 12*

*2. ការឆ្លងថ្មីនៃមេរោគអេដស៍នៅថ្នាក់ជាតិ ........ 13*

*3. ការប៉ាន់ស្មានចំនួនសរុបនៃអ្នកផ្ទុកមេរោគអេដស៍ ........ 13*

***4. ចំនួនសរុបនៃករណីស្លាប់ទាក់ទងនឹងមេរោគអេដស៍ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍** ........ 14*

ការប៉ាន់ស្មាន និងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍ នៅថ្នាក់ ក្រោមជាតិ ........ 15

*1. ចំនួនប្រជាជន នៅថ្នាក់ក្រោមជាតិ និង ផលធៀបតាមភេទ ........ 15*

*2. ការប៉ាន់ស្មាន និងការព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍ នៅថ្នាក់ក្រោមជាតិថ្នាក់ខេត្ត/ ........ 16*

*3. ការប៉ាន់ស្មានចំនួនករណីឆ្លងថ្មីនៃមេរោគអេដស៍ នៅថ្នាក់ក្រោមជាតិ ........ 18*

*4. ការប៉ាន់ស្មានចំនួនសរុបនៃករណីស្លាប់ទាក់ទងនឹងមេរោគអេដស៍ជំងឺអេដស៍ នៅថ្នាក់ក្រោមជាតិ/ ........ 20*

*5. ការប៉ាន់ស្មានអត្រាគ្របដណ្តប់នៃសេវា ART នៅថ្នាក់ក្រោមជាតិ ក្នុងឆ្នាំ២០១៥ ........ 22*

បញ្ហាគន្លឹះ និងការខ្វះខាតទិន្នន័យ ........ 25

បញ្ហាសំខាន់ៗ និងការសន្មតដែលប្រើសម្រាប់ធ្វើបច្ចុប្បន្នភាពគំរូគោល AEM ........ 25

ការខ្វះខាតទិន្នន័យសម្រាប់ការប៉ាន់ស្មាន និងព្យាករណ៍នៅថ្នាក់ខេត្ត ........ 27

*1. ការខ្វះខាតទិន្នន័យសម្រាប់កម្មវិធីបង្ការ ........ 27*

*2. ការខ្វះខាតទិន្នន័យ អំពីការថែទាំ និងការព្យាបាល ........ 27*

*3. ការខ្វះខាតទិន្នន័យអំពីទីតាំង ........ 27*

សន្និដ្ឋាន ........ 28

ឧបសម្ព័ន្ធ ........ 29

អត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍ក្នុងចំណោមស្ត្រីមកពិនិត្យផ្ទៃពោះ អាយុ < ២៥ ឆ្នាំ ........ 29

អត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍ក្នុងចំណោមស្ត្រីពិនិត្យផ្ទៃពោះ អាយុ > ២៥ឆ្នាំ ........ 30

អត្រាអាំងស៊ីដង់នៃមេរោគអេដស៍ក្នុងចំណោមអ្នកទទួលសេវា PRE-ART/ART តាមផល ធៀបភេទ (SEX RATIO) ........ 30

អត្រាអាំងស៊ីដង់នៃមេរោគអេដស៍ក្នុងចំណោមស្ត្រី នៅក្នុង ២៥ ខេត្ត ........ 31

អត្រាអាំងស៊ីដង់នៃមេរោគអេដស៍ក្នុងចំណោមប្រុស ក្នុង ២៥ ខេត្ត ........ 32

អត្រាអាំងស៊ីដង់សរុបនៃមេរោគអេដស៍ ក្នុង ២៥ ខេត្ត ........ 32

ឯកសារយោង ........ 33

# បញ្ជីតារាងនិងរូបភាព

តារាងទី១- ចំនួនប្រជាជននៃប្រទេសកម្ពុជា យោងតាម CIP 2013 .................... 16

តារាងទី២ - ការប៉ាន់ស្មាននិងព្យាករណ៍ចំនួនសរុបនៃមនុស្សពេញវ័យដែលផ្ទុកមេរោគអេដស៍ [អាយុ > ១៥ឆ្នាំ] នៅក្នុង ២៥ ខេត្ត .................... 17

តារាង៣ - ចំនួនករណីសរុបនៃការឆ្លងថ្មីនៃមេរោគអេដស៍ ក្នុងចំណោមមនុស្សពេញវ័យនៅក្នុង ២៥ ខេត្ត .................... 19

តារាងទី៤ - ចំនួនសរុបនៃករណីស្លាប់ទាក់ទងនឹងមេរោគអេដស៍ក្នុង ២៥ ខេត្ត .................... 21

តារាងទី៥ - ចំនួនសរុបនៃអ្នកផ្ទុកមេរោគអេដស៍ដែលទទួល ART និងអត្រាគ្របដណ្ដប់នៃ ART ក្នុងឆ្នាំ២០១៥ នៅក្នុង ២៥ ខេត្ត .................... 23

តារាងទី៦ - បញ្ហាគន្លឹះ និងការសន្មតសម្រាប់ធាតុចូលសំខាន់ៗ .................... 25

# បញ្ជីរូបភាព

រូបភាពទី១ - ចំនួនអ្នកផ្ទុកមេរោគអេដស៍(PLHIV) នៅក្នុង AEM និង Spectrum .................... 7

រូបភាពទី២ - ទំនោរនៃករណីឆ្លងថ្មីនៃមេរោគអេដស៍ព្យាករនៅក្នុងគំរូទាំងពីរ .................... 7

រូបភាពទី៣ - ទំនោរនៃការស្លាប់ទាក់ទងនឹងមេរោគអេដស៍ ព្យាករដោយគំរូទាំងពីរ .................... 8

រូបភាពទី៤ - វិធីប៉ាន់ស្មានផលធៀបស្រី និងប្រុស .................... 8

រូបភាពទី៥ - វិធីគណនាអាំងស៊ីដង់នៃមេរោគអេដស៍ថ្នាក់ខេត្តក្នុងចំណោមស្រីអាយុ > ១៥ ឆ្នាំ .................... 9

រូបភាពទី៦ - ការគណនាអាំងស៊ីដង់នៃមេរោគអេដស៍នៅថ្នាក់ខេត្តក្នុងចំណោមប្រុសអាយុ > ១៥ ឆ្នាំ .................... 10

រូបភាពទី៧ - ការប៉ាន់ស្មាននិងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍នៅថ្នាក់ក្រោមជាតិ ដោយប្រើ AEM និង Spectrum ... 11

រូបភាពទី៨ - ប្រេវ៉ាឡង់នៃមេរោគអេដស៍នៅថ្នាក់ជាតិ ការប៉ាន់ស្មានដោយប្រើគំរូ AEM និង Spectrum .................... 12

រូបភាពទី៩- ការឆ្លងថ្មីនៃមេរោគអេដស៍នៅថ្នាក់ជាតិ ព្យាករណ៍ដោយ AEM និង Spectrum .................... 13

រូបភាពទី១០- ចំនួនសរុបនៃអ្នកផ្ទុកមេរោគអេដស៍ពីឆ្នាំ ២០០៥ ដល់ឆ្នាំ២០២០ .................... 14

រូបភាពទី១១- ចំនួនសរុបនៃករណីស្លាប់ទាក់ទងនឹងមេរោគអេដស៍ និងក្រៅពីអេដស៍ ក្នុងចំណោមមនុស្សពេញវ័យដែលផ្ទុកមេរោគអេដស៍ ពីឆ្នាំ ២០១០-២០២០ .................... 15

# បញ្ជីពាក្យបំព្រួញ

| Abbreviation | Definition |
|---|---|
| AEM | Asian Epidemic Model |
| AIDS | Acquired Immune Deficiency Syndrome |
| ANC | Ante-Natal Care |
| ART | Anti-Retroviral Treatment |
| BSS | Behavioral Sentinel Surveillance |
| CHAI | Clinton Health Access Initiative |
| EPP | Estimation and Projection Package |
| EW | Entertainment Worker |
| FSW | Female Sex Worker |
| GFATM | Global Fund to fight AIDS, Tuberculosis and Malaria |
| HIV | Human Immunodeficiency Virus |
| IBBS | Integrated Biological and Behavioral Surveillance |
| IDU | Injecting Drug User |
| KP | Key Population |
| MARP | Most-at-Risk Population |
| MSM | Men who have Sex with Men |
| MSW | Men Sex Worker |
| NAA | National AIDS Authority |
| NCHADS | National center for HIV/AIDS, Dermatology and STD |
| NGO | None Governmental Organization |
| NIPH | National Institute of Public Health |
| PLHIV | People Living With HIV |
| PMTCT | Prevention of HIV Transmission from Mother to Child |
| PSK | Population Service Khmer |
| PWID | Person who inject Drugs, used interchangeably with IDU |
| SI | Strategic Information |
| STI | Sexual Transmitted Infection |
| TG | Transgender |
| TWG | Technical Working Group |
| UNAIDS | Joint United Nations Programme on HIV/AIDS |
| UNICEF | United Nations international children and education fund for Children's Fund |
| WHO | World Health Organization |

# សេចក្តីផ្តើម

## សាវតារ

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) បានអនុវត្តដោយជោគជ័យនូវការប៉ាន់ស្មាន និងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ចំនួនបួនលើកមកហើយ (ឆ្នាំ ២០០០, ២០០៣, ២០០៧, និងឆ្នាំ ២០១១) ដោយក្នុងនោះការព្យាករចុងក្រោយសម្រាប់រយៈពេលពីឆ្នាំ ២០១១ ដល់ ២០១៥ ។ ការអង្កេតទាំងបួនលើកនេះ ត្រូវបានធ្វើឡើងបន្ថែមពីលើការអង្កេតប៉ាន់ស្មាន និងព្យាករណ៍រាល់ពីរឆ្នាំម្តង ដែលធ្វើឡើងដោយ UNAIDS និង WHO ដើម្បីកសាងសមត្ថភាពរបស់ប្រទេសនៅក្នុងការប៉ាន់ស្មាន និងព្យាករណ៍ ព្រមទាំង ធ្វើបច្ចុប្បន្នភាពការប៉ាន់ស្មានថ្នាក់ជាតិ ដោយផ្អែកលើព័ត៌មានជាយុទ្ធសាស្ត្រ ដែលអាចប្រមូលបាននៅថ្នាក់ជាតិ។ ជុំចុងក្រោយនៃសិក្ខាសាលាស្តីពីការប៉ាន់ស្មាន និងព្យាករណ៍ថ្នាក់តំបន់ប្រចាំពីរឆ្នាំម្តង ត្រូវបានធ្វើឡើងក្នុងខែមីនា ឆ្នាំ២០១៥។

ដោយសារការធ្លាក់ចុះនៃការរាលដាលនៃមេរោគអេដស៍នៅក្នុងប្រទេសកម្ពុជា និងការឆ្លើយតបជាបន្តបន្ទាប់មក ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ ភាគីពាក់ព័ន្ធបានចាប់ផ្តើមធ្វើការវិភាគផ្អែកអេពីដេមីសាស្ត្រ និងផ្អែកកម្មវិធី នៅថ្នាក់ក្រោមជាតិ។ ដូច្នេះ កម្មវិធីនេះត្រូវការការប៉ាន់ស្មាននិងព្យាករណ៍ជាក់លាក់តាមខេត្តនីមួយៗ ដើម្បីណែនាំដល់ការអនុវត្តកម្មវិធី និងតាមដានការឆ្លើយតបនៅថ្នាក់ក្រោមជាតិ ខណៈពេលដែលកម្មវិធីនេះ ឈានទៅសម្រេចគោលដៅថ្នាក់ជាតិ នៃការលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍។ កិច្ចការនេះ តម្រូវឲ្យមានការធ្វើការប៉ាន់ស្មាន និងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេស៍/អ្នកជំងឺអេដស៍ សម្រាប់រយៈពេលពីឆ្នាំ២០១៦ ដល់ ២០២០ និង បណ្តាឆ្នាំខាងមុខ ព្រមទាំងបង្កើតការប៉ាន់ស្មានចំនួនអ្នកផ្ទុកមេរោគអេដស៍នៅថ្នាក់ក្រោមជាតិ ជាលើកដំបូង ផងដែរ។

ដោយសារហេតុផលនេះ នៅខែកុម្ភៈ ឆ្នាំ២០១៦ សិក្ខាសាលារយៈពេលមួយសប្តាហ៍ ត្រូវបានរៀបចំឡើងដើម្បីធ្វើបច្ចុប្បន្នភាពនៃការប៉ាន់ស្មាន និងព្យាករណ៍ថ្នាក់ជាតិ ព្រមទាំងដាក់ចេញនូវចំនួនប៉ាន់ស្មានថ្នាក់ក្រោមជាតិ ដោយប្រើឧបករណ៍ AEM និង Spectrum ។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្រោមការដឹកនាំរបស់ NCHADS ដោយមានការណែនាំពីក្រុមការងារបច្ចេកទេសនៃព័ត៌មានជាយុទ្ធសាស្ត្រ (SI-TWG) និងមានការចូលរួមពីភាគីពាក់ព័ន្ធសំខាន់ៗ ដែលរួមមាន NAA, NIPH, UNAIDS, USD-CDC, PEPFAR, CHAI, KHANA, FHI 360, PSK និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជាច្រើនទៀតដែលធ្វើការទាក់ទងនឹងកម្មវិធីអេដស៍។ សិក្ខាសាលានេះ គាំទ្រដោយអង្គការ UNAIDS ដោយមានជំនួយបច្ចេកទេសពីមជ្ឈមណ្ឌលខាងកើត-ខាងលិច (East-West Center) ដែលតំណាងដោយបណ្ឌិត Wiwat Peerapatanapokin និង សម្របសម្រួលដោយទីប្រឹក្សាបច្ចេកទេសជាតិ លោកវេជ្ជ.ខៀវ គឹមលី ។

វិធីសាស្រ្តចម្បងដែលបានអនុវត្តសម្រាប់ការប៉ាន់ស្មាន និងព្យាករណ៍ រួមមាន ការពិនិត្យឡើងវិញលើទិន្នន័យចុងក្រោយបំផុតដែលពាក់ព័ន្ធប្រមូលបានពីការអង្កេត/ការតាមដាន ការសិក្សាស្រាវជ្រាវ កម្មវិធី និងគម្រោងនានា ដើម្បីជាមូលដ្ឋានសម្រាប់ឧបករណ៍ AEM និង spectrum ដែលបានធ្វើបច្ចុប្បន្នភាពថ្មី ព្រមទាំងឯកភាពគ្នាលើការប្រើប្រាស់ ការសន្មតដោយផ្អែកលើព័ត៌មានដែលមាន និងក្នុងករណីមានការខ្វះខាតទិន្នន័យ។

## សេចក្តីសង្ខេបអំពីស្ថានភាពមេរោគអេដស៍/ជំងឺអេដស៍

ដោយប្រឈមមុខនឹងការឆ្លងរាលដាលមេរោគអេដស៍ដ៏ឆាប់រហ័ស នៅក្នុងទ្វីបអាស៊ី កាលពីពាក់កណ្តាលទសវត្សរ៍ ១៩៩០ កម្ពុជាស្ថិតនៅក្នុងចំណុចរបត់ដ៏សំខាន់មួយ នៃការឆ្លើយតបនឹងមេរោគអេដស៍ ។ នៅក្នុងទសវត្សរ៍ទីបីនៃការឆ្លើយតបនឹងមេរោគអេដស៍បានរំកិលចូលទៅក្នុងដំណាក់កាលលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ ដោយក្នុងនោះមានការឆ្លងថ្មីតិចជាង ១០០០ ករណីក្នុងមួយឆ្នាំ ចាប់តាំងពីឆ្នាំ២០១៣ [1]។ ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ កម្ពុជាបានក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសមួយចំនួនតូច ដែលបានបង្វិលទិសដៅមេរោគអេដស៍ឲ្យត្រឡប់ក្រោយវិញ ដោយក្នុងនោះ អត្រាប្រេវ៉ាឡង់មេរោគអេដស៍បានធ្លាក់ចុះពីប្រមាណ ១,៧% (ក្នុងចំណោមមនុស្សពេញវ័យអាយុ ១៥-៤៩ឆ្នាំ) ក្នុងឆ្នាំ១៩៩៨ [2] មកត្រឹម ០,៦% ក្នុងឆ្នាំ២០១៥ [3]។ ការឆ្លងថ្មីនៃមេរោគអេដស៍បានធ្លាក់ចុះយ៉ាងខ្លាំងក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ ហើយកម្ពុជា សម្រេចបានអត្រាគ្របដណ្តប់ការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ខ្ពស់ គឺ ៧៤,៥% ក្នុងឆ្នាំ២០១៥ ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ [4]។

រួមជាមួយការធ្លាក់ចុះនៃអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅ គេបានកត់សម្គាល់ថា ក្រុមប្រជាជនចំណុច (KP) ដូចជា ស្រ្តីបម្រើសេវាកំសាន្ត (EW), អ្នកប្រើប្រាស់គ្រឿងញៀន អ្នកបំប្លែងភេទ (TG) និងបុរសរួមភេទជាមួយបុរស (MSM) នៅតែជាក្រុមដែលងាយរងគ្រោះបំផុត ដែលត្រូវការការយកចិត្តទុកដាក់ជាពិសេស ក្នុងការផ្តល់សេវាបង្ការ ថែទាំ និងព្យាបាល។ ខណៈដែលអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមស្រ្តីបម្រើសេវាកំសាន្ត បានធ្លាក់ចុះពី ២០,៨% ក្នុងឆ្នាំ២០០៣ មកត្រឹម ១៤% ក្នុងឆ្នាំ២០១០ [5], ថ្មីៗនេះគេសង្កេតឃើញមានទំនោរកើនឡើងក្នុងចំណោមក្រុមបុរសរួមភេទជាមួយបុរស និងក្រុមអ្នកបំប្លែងភេទ [MSM-២,១៦% ក្នុងឆ្នាំ២០១០ ដល់ ២,៣% ក្នុងឆ្នាំ២០១៥ និង TG ៤,៦% ក្នុងឆ្នាំ២០១២ ដល់ ៥,៩% ក្នុងឆ្នាំ២០១៦] [3, 6, 7, 8]. អ្នកចាក់គ្រឿងញៀន (PWID) នៅតែមានប្រេវ៉ាឡង់ខ្ពស់ គឺ ២៤,៤% ដោយផ្អែកលើការអង្កេត IBBS ក្នុងឆ្នាំ២០១២

[9]។ ការឆ្លើយតបថ្នាក់ជាតិ គឺផ្តោតទៅលើក្រុមប្រជាជនចំណុច ដែលប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ តាមរយៈការដាក់ឲ្យអនុវត្តយុទ្ធសាស្ត្រគំនិតផ្តួចផ្តើមថ្មីៗ និងដែលមានប្រសិទ្ធផលខ្ពស់ដើម្បីផ្តល់សេវាបង្ការ និងព្យាបាលមេរោគអេដស៍ដល់ក្រុមប្រជាជនចំណុចដែលលាក់មុខ ។

យោងតាមការប៉ាន់ស្មាននិងព្យាករណ៍បច្ចុប្បន្ន ដោយប្រើឧបករណ៍ Spectrum V5.4, មានអ្នករស់នៅជាមួយមេរោគអេដស៍ប្រមាណ ៧២ ៦០១នាក់ (PLHIV) នៅក្នុងប្រទេសកម្ពុជា នៅចុងឆ្នាំ២០១៥ [10]។ ដោយមានការអនុវត្តជាបន្តនូវអន្តរាគមន៍បង្ការផ្តោតលើគោលដៅប្រកបដោយប្រសិទ្ធភាព រួមជាមួយនឹងការពង្រីកអត្រាគ្របដណ្តប់ខ្ពស់នូវសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ កម្ពុជាត្រៀមខ្លួនដើម្បីក្លាយជាប្រទេសដែលមានប្រាក់ចំណូលទាបទី១ ក្នុងការឈានទៅសម្រេចបានគោលដៅសកល ៩០-៩០-៩០ នៅឆ្នាំ២០២០ និងឈានទៅសម្រេចការលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍នៅ ឆ្នាំ២០២៥។

## ប្រភពទិន្នន័យសំខាន់ៗដែលត្រូវប្រើសម្រាប់ប៉ាន់ស្មាន និងព្យាករណ៍

នៅពេលចាប់ផ្តើមសិក្ខាសាលា ក្រុមការងារបច្ចេកទេសព័ត៌មានជាយុទ្ធសាស្ត្រ [ដែលមានតំណាងមកពី NCHADS, NAA, UNAIDS, WHO, US-CDC, CHAI, FHI, KHANA, PSK, ទីប្រឹក្សាបច្ចេកទេសជាតិនិងអន្តរជាតិ] បានកំណត់ និងពិភាក្សាពីប្រភពទិន្នន័យផ្សេងៗសម្រាប់ធ្វើបច្ចុប្បន្នភាពគំរូទិន្នន័យគោល AEM ដែលបានធ្វើឡើងក្នុងឆ្នាំ២០១៤ និងទិន្នន័យដែលត្រូវការសម្រាប់រៀបចំសំណុំឯកសារ Spectrum ថ្នាក់ខេត្ត ដែលជាមូលដ្ឋាននៃការប៉ាន់ស្មាន និងព្យាករណ៍ចំនួនអ្នករស់នៅជាមួយមេរោគអេដស៍នៅថ្នាក់ខេត្ត។ នៅក្នុងដំណើរការនេះ ប្រភពទិន្នន័យជាច្រើនត្រូវបានកំណត់ និងយកមកពិនិត្យពិភាក្សា ហើយទិន្នន័យពីប្រភពទាំងអស់នេះត្រូវបានឯកភាពគ្នាដើម្បីដាក់បញ្ចូលទៅក្នុងគំរូ ក៏ដូចជាការសន្មតមួយចំនួនផ្អែកលើព័ត៌មានដែលមាន សម្រាប់ទិន្នន័យ/ព័ត៌មានដែលមិនទាន់មាន។ ប្រភពទិន្នន័យសំខាន់ៗ ដែលបានឯកភាពគ្នាសម្រាប់ការប៉ាន់ស្មាននេះ ដោយប្រើឧបករណ៍ Spectrum និង AEM មានដូចខាងក្រោម៖

1. **ការអង្កេត ANC និង ការអង្កេត IBBS** [11]: ការអង្កេត ANC និង ការអង្កេត IBBS ក្នុងចំណោមក្រុម MSM និង TG ដែលបានធ្វើឡើងក្នុងឆ្នាំ២០១៤ និង ២០១៥ ត្រូវបានយកមកប្រើប្រាស់ដើម្បីធ្វើបច្ចុប្បន្នភាពព័ត៌មានពាក់ព័ន្ធនៅក្នុងទិន្នន័យ AEM សម្រាប់ក្រុម MSM និង TG ។ ប្រេវ៉ាឡង់មេរោគអេដស៍នៃការអង្កេត ANC ក្នុងឆ្នាំ២០១៤ រួមជាមួយទិន្នន័យឆ្នាំកន្លងទៅ ត្រូវបានប្រើ

ប្រាស់នៅក្នុងការដាក់ចេញនូវអត្រាអាំងស៊ីដង់ លើស្រី និងប្រុសនៅថ្នាក់ជាតិ សម្រាប់ការប្រើប្រាស់នៅក្នុង Spectrum សម្រាប់ធ្វើការប៉ាន់ស្មាននៅថ្នាក់ក្រោមជាតិ។

2. **ស្ថិតិប្រជាជនរបស់អង្គការសហប្រជាជាតិ និងការអង្កេតប្រជាជនអន្តរជំរឿនកម្ពុជា ឆ្នាំ២០១៣** [10, 12]៖ ស្ថិតិប្រជាជនរបស់អង្គការសហប្រជាជាតិ បានមកពីការិយាល័យប្រជាជនអង្គការសហប្រជាជាតិ ត្រូវបានប្រើប្រាស់ដើម្បីដាក់ចេញជា ចំនួនប្រជាជនសរុបតាមឆ្នាំ ចាប់ពីឆ្នាំ១៩៧០ ដល់ ២០៥០ ដែលត្រូវការដោយឧបករណ៍ AEM និង Spectrum ។ សមាមាត្រស្ត្រីធៀបនឹងប្រុស និង ស្ថិតិប្រជាជនសរុបក្នុងខេត្ត ត្រូវបានទទួលពី CIP ឆ្នាំ២០១៣។ ស្ថិតិប្រជាជនពីប្រភពទាំងពីរនេះ ត្រូវបានប្រៀបធៀប និងធ្វើការកែតម្រូវចំនួនប្រជាជននៅថ្នាក់ជាតិនិងខេត្ត ដើម្បីឲ្យត្រូវតាមចំនួនប្រជាជនសរុបដែលប៉ាន់ស្មានសម្រាប់ឆ្នាំ២០១៥ និងព្យាករណ៍រហូតដល់ឆ្នាំ២០៥០។

3. **របាយការណ៍កម្មវិធី ART** [13]៖ NCHADS រក្សាទុកប្រព័ន្ធទិន្នន័យមូលដ្ឋាននៃ ART ដែលចងក្រង និងរក្សាទុកទិន្នន័យដែលប្រមូលពីសេវា ART ទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ប្រព័ន្ធទិន្នន័យមូលដ្ឋាន ត្រូវបានប្រើចាប់តាំងពីឆ្នាំ២០០៥ និងទិន្នន័យសំខាន់ៗអំពី PLHIV ដែលទទួលការព្យាបាលដោយ ART/regimen ហើយអថេរផ្សេងទៀត ក៏មាននៅក្នុងទិន្នន័យមូលដ្ឋាននេះដែរ។ ទោះបីជាយ៉ាងណាក្តី សម្រាប់សេវា ART ដែលបង្កើតថ្មីក្នុងខេត្តមួយចំនួន នៅមិនទាន់មានទិន្នន័យទេ។ ដូច្នេះ ការទាញយកព័ត៌មានដែលពាក់ព័ន្ធ ត្រូវបានយកមកប្រើជំនួសវិញ។ ឧទាហរណ៍ សម្រាប់ខេត្តត្បូងឃ្មុំ កែប និងមណ្ឌលគិរី ត្រូវយកចំនួនតំណាងពីខេត្តជិតខាង ឬខេត្តដើម មកប្រើប្រាស់ ដើម្បីដាក់ចេញផលធៀបបុរស និងស្រីដែលកំពុងប្រើប្រាស់សេវា ART ។ របាយការណ៍ ART ប្រចាំឆ្នាំរបស់ NCHADS ត្រូវបានយកមកប្រើ ដើម្បីធ្វើបច្ចុប្បន្នភាពអត្រាគ្របដណ្តប់ការព្យាបាលនៅក្នុង AEM និង Spectrum ត្រឹមខែធ្នូ ឆ្នាំ២០១៥។

## គោលបំណង

គោលបំណងចម្បងនៃសិក្ខាសាលានៃការប៉ាន់ស្មាន និងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍ គឺដើម្បី៖

- ធ្វើបច្ចុប្បន្នភាពការប៉ាន់ស្មាន និងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍សម្រាប់ឆ្នាំ២០១៦-២០២០ និងបណ្តាឆ្នាំខាងមុខ។
- ការប៉ាន់ស្មានចំនួនអ្នកផ្ទុកមេរោគអេដស៍ថ្នាក់ខេត្ត អាំងស៊ីដង់នៃមេរោគអេដស៍ និងអត្រាស្លាប់ទាក់ទងនឹងមេរោគអេដស៍។
- កសាងសមត្ថភាពជាតិសម្រាប់ធ្វើការប៉ាន់ស្មាន និងព្យាករណ៍ ដោយប្រើកម្មវិធី AEM និង Spectrum software ។

## វិធីសាស្រ្ត

ក្នុងអំឡុងពេលសិក្ខាសាលារយៈពេលប្រាំថ្ងៃ (១៥-១៩ កុម្ភៈ ២០១៦) ក្រុមការងារបច្ចេកទេសព័ត៌មានជាយុទ្ធសាស្រ្ត បានពិភាក្សាគ្នា និងកំណត់ពីដំណើរការរៀបចំ/ប្រមូលធាតុចូលទិន្នន័យសំខាន់ៗសម្រាប់គំរូ AEM និង Spectrum Models ដើម្បីធ្វើបច្ចុប្បន្នភាពចំនួនប៉ាន់ស្មាន និងព្យាករណ៍ថ្នាក់ជាតិ ព្រមទាំងដាក់ចេញនូវ ការប៉ាន់ស្មានចំនួនអ្នកផ្ទុកមេរោគអេដស៍នៅថ្នាក់ខេត្ត។ វិធីសាស្រ្តត្រូវបានអនុវត្តជាជំហានសំខាន់ៗ ដូចខាងក្រោម៖

## ធ្វើបច្ចុប្បន្នភាពការប៉ាន់ស្មាន និងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍នៅថ្នាក់ជាតិ

### 1. ធ្វើបច្ចុប្បន្នភាពការប៉ាន់ស្មានទំហំក្រុមប្រឈមមុខ ឥរិយាបថផ្លូវភេទ និងប្រេវ៉ាឡង់នៅក្នុង AEM ២០១៤

ឧបករណ៍គំរូ AEM ត្រូវបានគេប្រើនៅពាក់កណ្តាលឆ្នាំ២០១៤ ដើម្បីប៉ាន់ស្មាន និងព្យាករណ៍ប្រេវ៉ាឡង់នៃមេរោគអេដស៍សម្រាប់ថ្នាក់ជាតិ។ សម្រាប់លំហាត់បច្ចុប្បន្ននេះ ជំហានទី១គឺ ត្រូវធ្វើបច្ចុប្បន្នភាពធាតុចូលសំខាន់ៗសម្រាប់គំរូ AEM ដោយកំណត់ឆ្នាំ២០១៤ជាឆ្នាំដើមគ្រា (baseline) ជាមួយទិន្នន័យដែលមានចុងក្រោយ។ ជំហាននេះ រួមបញ្ចូលទាំងការធ្វើបច្ចុប្បន្នភាពទិន្នន័យអំពីទំហំក្រុម MSM, ព័ត៌មានអំពីការប្រព្រឹត្តិរបស់ក្រុម MSM និង TG ដោយប្រើទិន្នន័យថ្មីដែលទទួលបានពីការសិក្សាចុងក្រោយក្នុងឆ្នាំ២០១៤-១៥។ ប្រេវ៉ាឡង់នៃមេរោគអេដស៍ក្នុងចំណោមក្រុម MSM និង TG ក៏

ត្រូវបានធ្វើបច្ចុប្បន្នភាពផងដែរ ដោយផ្អែកលើទិន្នន័យដែលមានចុងក្រោយ។ បន្ថែមពីលើនេះ ចំនួនអ្នកជំងឺដែលបានទទួល ART ក្នុងឆ្នាំ២០១៤ និង ២០១៥ ត្រូវបានធ្វើបច្ចុប្បន្នភាពទៅក្នុងគំរូ AEM ។

## 2. ការរៀបចំដំណើរការ AEM 4.1 និង SPECTRUM V5.4 ដោយប្រើឧបករណ៍ AEM-SPECTRUM Fitting Tool

ចាប់តាំងពីការប្រើប្រាស់វិធីសាស្រ្ត AEM នៅឆ្នាំ២០១៤ ដោយប្រើ Version 4.0, តម្រូវឲ្យប្តូរទៅប្រើ Version ចុងក្រោយបំផុតគឺ (4.1)។ បន្ទាប់ពីប្តូរទៅប្រើទម្រង់ថ្មីនៃឧបករណ៍ AEM Version 4.1 និង Spectrum Version 5.4 ត្រូវបានប្រើដើម្បីបំពេញលទ្ធផលបច្ចុប្បន្នភាពពី AEM ។ ឧបករណ៍ AEM-Spectrum fitting tool ត្រូវបានប្រើដើម្បីរៀបចំដំណើរការលទ្ធផល Spectrum ឲ្យស្របជាមួយលទ្ធផល AEM ។ សូចនាករសំខាន់ៗសម្រាប់ការដាក់តម្រូវនេះ គឺចំនួនមនុស្សពេញវ័យដែលផ្ទុកមេរោគអេដស៍ ចំនួនអ្នកឆ្លងមេរោគអេដស៍ថ្មី និងចំនួនករណីស្លាប់។ ខាងក្រោមនេះគឺជាជំហាននីមួយៗដើម្បីរៀបចំដាក់ដំណើរការ (calibrate) ឧបករណ៍ទាំងពីរនេះ៖

ជំហានទី១៖ ដាក់បញ្ចូល (Upload) AEM V4.1 ទៅក្នុង Spectrum V5.4 ដោយចាប់ផ្តើមពីអាំងស៊ីដង់នៃមេរោគអេដស៍ ។

ជំហានទី២៖ លទ្ធផលចុងក្រោយនៃ AEM ត្រូវបានប្រើដើម្បីប្រៀបធៀបជាមួយ Spectrum ជាមួយក្រុមឆ្នាំដូចគ្នា។

ជំហានទី៣៖ ចម្លង(copy)លទ្ធផលសង្ខេបនៃចំនួនមនុស្សពេញវ័យដែលផ្ទុកមេរោគអេដស៍ដែលមានអាយុលើសពី ១៥ឆ្នាំ និងយកមកដាក់ (paste) ក្នុងឧបករណ៍តម្រូវនេះ (fitting tool)។

ជំហានទី៤៖ ដាក់តម្រូវ (Fitting) Spectrum ដើម្បីឲ្យលទ្ធផលស្របជាមួយលទ្ធផលរបស់ AEM ដោយប្រើប៉ារ៉ាម៉ែត្រអន្តរកាល និងអត្រាមរណភាពនៅក្នុងជម្រើសកម្រិតខ្ពស់របស់ Spectrum (advanced options)។

## 3. AEM-Spectrum បន្ទាប់ពីរៀបចំដាក់ឲ្យដំណើរការ (calibration)

បន្ទាប់ពីរៀបចំដាក់ឲ្យដំណើរការ (calibration) ចំនួនករណីឆ្លងថ្មីនៃមេរោគអេដស៍ និងប្រេវ៉ាឡង់នៃមេរោគអេដស៍ ដែលបង្កើតឡើងដោយគំរូទាំងពីរគឺ មានលក្ខណៈស្រដៀងគ្នា។ នេះមានន័យថា គំរូ Spectrum និង AEM ត្រៀមរួចរាល់សម្រាប់ប្រើនៅក្នុងការព្យាករណ៍ ការប៉ាន់ស្មានចំនួនអ្នកផ្ទុកមេរោគអេដស៍នៅថ្នាក់ក្រោមជាតិ។ រូបភាពទី១ ទី២ និង ទី៣ បង្ហាញពីភាពត្រូវគ្នាល្អបំផុតរវាងខ្សែកោង AEM និង Spectrum ។

*រូបភាពទី ១ - ចំនួនអ្នកផ្ទុកមេរោគអេដស៍ (PLHIV) នៅក្នុង AEM និង Spectrum*




*រូបភាពទី ២ - ទំនោរនៃករណីឆ្លងថ្មីនៃមេរោគអេដស៍ព្យាករណ៍នៅក្នុងគំរូទាំងពីរ*



*រូបភាពទី ៣ - ទំនោរនៃការស្លាប់ទាក់ទងនឹងមេរោគអេដស៍ ព្យាករណ៍ដោយគំរូទាំងពីរ*




# ការប៉ាន់ស្មាន និងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍ នៅថ្នាក់ក្រោមជាតិ

## 1. រៀបចំ "ទិន្នន័យប្រជាសាស្ត្រ" ដែលត្រូវប្រើជាធាតុចូលសម្រាប់ Spectrum នៅថ្នាក់ក្រោមជាតិ ២៥ ខេត្ត

ទិន្នន័យជំរឿនប្រជាជនថ្នាក់ជាតិចុងក្រោយបំផុត គឺឆ្នាំ២០០៨ ដូច្នេះក្រុមការងារបានសម្រេចប្រើទិន្នន័យបានមកពីការអង្កេតប្រជាជនអន្តរជំរឿនកម្ពុជា (CIP) ដែលបានធ្វើឡើងក្នុងឆ្នាំ២០១៣ ដើម្បីបង្កើតសមាមាត្រប្រជាជនថ្នាក់ខេត្ត និងផលធៀបប្រុសនិងស្រីនៅថ្នាក់ខេត្ត។ សមាមាត្រថ្នាក់ខេត្តសម្រាប់ប្រុសនិងស្រីនេះ ត្រូវបានប្រើប្រាស់ដើម្បីប្តូរប្រជាសាស្ត្រថ្នាក់ជាតិនៅក្នុង Spectrum សម្រាប់ប្រជាសាស្ត្រជាក់លាក់តាមខេត្តនៅក្នុង Spectrum ។ បន្ទាប់មក តួលេខប្រជាជនឆ្នាំ២០១៣ នៅក្នុង Spectrum ត្រូវបានប្រៀបធៀបគ្នា និងផ្ទៀងផ្ទាត់ជាមួយតួលេខប្រជាជនថ្នាក់ខេត្តនៃ CIP-2013 ។

*រូបភាពទី ៤ - វិធីប៉ាន់ស្មានផលធៀបស្រី និងប្រុស*



## 2. ការប៉ាន់ស្មានអាំងស៊ីដង់មេរោគអេដស៍នៅថ្នាក់ខេត្តក្នុងចំណោមស្ត្រី អាយុលើសពី ១៥ឆ្នាំ

បន្ទាប់ពីពិនិត្យឡើងវិញលើទិន្នន័យដែលមានសម្រាប់នៅថ្នាក់ក្រោមជាតិ គេបានឯកភាពគ្នាថា ប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះ អាចត្រូវបានប្រើសម្រាប់ដំណើរការប៉ាន់ស្មាននេះ ។ រូបភាពទី៥ បង្ហាញពីវិធីសាស្ត្រដើម្បីកំណត់អាំងស៊ីដង់នៃមេរោគអេដស៍ក្នុងចំណោមស្ត្រី អាយុលើសពី ១៥ឆ្នាំ ដោយផ្អែកលើទិន្នន័យដែលបានមកពីការអង្កេតតាមដាន ANC ។ ស្ត្រីមានផ្ទៃពោះអាយុតិចជាង២៥ឆ្នាំ ត្រូវបានប្រើប្រាស់ដើម្បីបង្កើតអត្រាអាំងស៊ីដង់មេរោគអេដស៍ ពីព្រោះមានទិន្នន័យសម្រាប់ខេត្តភាគច្រើន ក្នុងរយៈពេលជាច្រើនឆ្នាំ។ បន្ទាប់មក ធ្វើមធ្យមភាគរំកិល៣ឆ្នាំ ត្រូវបានអនុវត្តចំពោះប្រេវ៉ាឡង់ ANC ដោយរលូន បន្ទាប់មក របាយករណីឆ្លងថ្មីនៃមេរោគអេដស៍ក្នុងចំណោមស្ត្រី ជាសមាមាត្រទៅតាមខេត្តនីមួយៗ សម្រាប់ទាំង ២៥ រាជធានី/ខេត្ត។

*រូបភាពទី ៥ - វិធីគណនាអាំងស៊ីដង់នៃមេរោគអេដស៍ថ្នាក់ខេត្តក្នុងចំណោមស្ត្រីអាយុ>១៥ឆ្នាំ*




## 3. ការប៉ាន់ស្មានអាំងស៊ីដង់មេរោគអេដស៍ក្នុងចំណោមប្រុស អាយុ > ១៥ឆ្នាំ

ការគណនាអាំងស៊ីដង់មេរោគអេដស៍ក្នុងចំណោមប្រុសអាយុលើសពី ១៥ឆ្នាំ គឺមានការលំបាក។ ក្រុមអ្នកស្រាវជ្រាវបានពិនិត្យឡើងវិញលើទិន្នន័យដែលមានស្រាប់ បានមកពីករណី HIV-TB, ការបរិច្ចាគឈាម ។ល។ ទោះបីជាយ៉ាងណាក្តី ទិន្នន័យសេវា pre-ART/ART បានពី NCHADS ត្រូវបានឯកភាពគ្នាថា មានលក្ខណៈពេញលេញ និងត្រឹមត្រូវជាង ហើយអាចប្រើប្រាស់បានច្រើនជាងគេក្នុងចំណោមប្រភពទិន្នន័យទាំងអស់។ រូបភាពទី៦ ខាងក្រោមនេះ បង្ហាញពីវិធីសាស្ត្រដើម្បីប៉ាន់ស្មានអាំងស៊ីដង់នៃមេរោគអេដស៍ក្នុងចំណោមប្រុសអាយុ > ១៥ឆ្នាំ។ ទិន្នន័យអំពីចំនួនអ្នកដែលបានចុះឈ្មោះនៅសេវា Pre-ART/ART ត្រូវបានប្រើប្រាស់សម្រាប់ដំណើរការនេះ។ ផ្អែកលើទិន្នន័យនេះ ផលធៀប

ភេទ និងវិធីសាស្រ្ត smoothing ដោយប្រើមធ្យមភាគរំកិល៣ឆ្នាំ ត្រូវបានអនុវត្ត ហើយអាំងស៊ីដង់ត្រូវបានកំណត់។

*រូបភាពទី៦-ការគណនាអាំងស៊ីដង់នៃមេរោគអេដស៍នៅថ្នាក់ខេត្តក្នុងចំណោមមនុស្សប្រុសអាយុ> ១៥ឆ្នាំ*




## 4. ការប្រើគំរូ AEM និង Spectrum សម្រាប់ប៉ាន់ស្មាន និងព្យាករណ៍នៅថ្នាក់ក្រោមជាតិ

វិធីដើម្បីកំណត់ការប៉ាន់ស្មាន និងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍នៅថ្នាក់ក្រោមជាតិ គឺត្រូវធ្វើការជាមួយ Spectrum និង AEM ។ នៅដំណាក់កាលនេះ ការប៉ាន់ស្មាន និងព្យាករណ៍នៅថ្នាក់ក្រោមជាតិត្រូវបានកំណត់ ដោយប្រើការរួមបញ្ចូលរវាង Spectrum និង AEM ។ ទីមួយ ចំនួនប្រជាជន និងអាំងស៊ីដង់នៃមេរោគអេដស៍នៅក្នុងខេត្តនីមួយៗ ត្រូវកំណត់ម្តងមួយៗ។ ទីពីរ AEM ត្រូវបានប្រើប្រាស់ដើម្បីបង្កើតអាំងស៊ីដង់នៃមេរោគអេដស៍សរុបក្នុងចំណោម ប្រុស និងស្រី ដោយចាប់ផ្តើមពីឆ្នាំ១៩៧០ ដល់ឆ្នាំ២០៥០។ ទីបី ផលធៀបនៃអាំងស៊ីដង់ ត្រូវបានកែតម្រូវ ៤% ចុះពី Spectrum ដោយសារតែវិធី fitting method នៅក្នុង AEM ដោយប្រើប្រាស់ទិន្នន័យនៃមនុស្សពេញវ័យអាយុ > ១៥ឆ្នាំ ដែលផ្ទុកមេរោគអេដស៍ និងលទ្ធផលសង្ខេបនៃ ART។ ចុងក្រោយ ការប៉ាន់ស្មាននិងព្យាករណ៍នៅថ្នាក់ក្រោមជាតិ ត្រូវបានកំណត់នៅក្នុងទម្រង់ AEM ដោយចាប់ផ្តើមពីឆ្នាំ១៩៧០ ដល់ ២០៥០ ដែលពិពណ៌នាក្នុងដ្យាក្រាមខាងក្រោម។

*រូបភាពទី ៧ - ការប៉ាន់ស្មាននិងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍នៅថ្នាក់ក្រោមជាតិ ដោយប្រើ AEM និង*



# លទ្ធផល

## ការប៉ាន់ស្មាន និងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍ថ្នាក់ជាតិ

### 1. ប្រេវ៉ាឡង់នៃមេរោគអេដស៍នៅថ្នាក់ជាតិ

អត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍នៅថ្នាក់ជាតិ បាននិងកំពុងធ្លាក់ចុះ បន្ទាប់ពីឡើងដល់កម្រិតកំពូលក្នុងឆ្នាំ១៩៩៨។ រូបភាពទី៨ ខាងក្រោមបង្ហាញយ៉ាងច្បាស់ពីទំនោរប្រេវ៉ាឡង់នៃមេរោគអេដស៍ដែលបានធ្លាក់ចុះបន្តិចម្តងៗពី ១,៦% ក្នុងឆ្នាំ១៩៩៨ មកត្រឹម ០,៦% ក្នុងឆ្នាំ២០១៥។ ពីឆ្នាំ២០១៥ ដល់ ២០២០ ទំនោរហាក់ដូចជាធ្លាក់ចុះដោយសន្សឹមៗបន្ថែមទៀត។ ការព្យាករណ៍ដោយប្រើគំរូ AEM/Spectrum នៅដើមឆ្នាំ២០១៦ បង្ហាញទំនោរធ្លាក់ចុះដូចគ្នាក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ និងការព្យាករណ៍អត្រាប្រេវ៉ាឡង់ ០,៥% ត្រឹមឆ្នាំ២០២០។

*រូបភាពទី ៨ - ប្រេវ៉ាឡង់នៃមេរោគអេដស៍នៅថ្នាក់ជាតិ ការប៉ាន់ស្មានដោយប្រើគំរូ AEM និង Spectrum*



## 2. ការឆ្លងថ្មីនៃមេរោគអេដស៍នៅថ្នាក់ជាតិ

ទំនោរនៃការឆ្លងថ្មីនៃមេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅ មានការធ្លាក់ចុះចាប់ពីឆ្នាំ២០០៥។ ទំនោរនេះបន្តធ្លាក់ចុះចាប់ពីឆ្នាំ២០១០។ ជាលទ្ធផល ចំនួនករណីឆ្លងថ្មីនៃមេរោគអេដស៍សរុបក្នុងឆ្នាំ ២០១៥ គឺមានប្រមាណ ៧១៥ករណីក្នុងចំណោមកុមារ និងមនុស្សពេញវ័យអាយុ > ១៥ ឆ្នាំ។ ទំនោរនេះបានធ្លាក់ចុះសន្សឹមៗមកប្រមាណ ៤៧៤ ករណី នៅឆ្នាំ២០២០។ (សូមមើលរូបភាពទី៩)។

*រូបភាពទី ៩ - ការឆ្លងថ្មីនៃមេរោគអេដស៍នៅថ្នាក់ជាតិ ព្យាករណ៍ដោយ AEM និង Spectrum*




## 3. ការប៉ាន់ស្មានចំនួនសរុបនៃអ្នកផ្ទុកមេរោគអេដស៍

រូបភាពទី១០ បង្ហាញពីចំនួនសរុបនៃអ្នកផ្ទុកមេរោគអេដស៍ (PLHIV) ពីឆ្នាំ២០០៥ ដល់ ២០២០។ នៅក្នុងឆ្នាំ២០១៥ មានអ្នកផ្ទុកមេរោគអេដស៍ប្រមាណ ៧២.៦០៧ នាក់ តួលេខប៉ាន់ស្មាននេះនឹងធ្លាក់ចុះមកត្រឹម ៦២.៥០០ នាឆ្នាំ២០២០ ជាពិសេសដោយសារមានការធ្លាក់ចុះករណីឆ្លងថ្មីនៃមេរោគអេដស៍ និងការស្លាប់។ ទោះបីជាយ៉ាងណាក្តី គេត្រូវកត់សម្គាល់ថា ការឆ្លងថ្មី និងការស្លាប់ដែលទាក់ទងនឹងមេរោគអេដស៍ជារួម បានធ្លាក់ចុះយ៉ាងច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ ផ្នែកមួយនៃការស្លាប់ ក៏ដោយសារតែជរាភាពរបស់អ្នកផផ្ទុកមេរោគអេដស៍។

*រូបភាពទី ១០ - ចំនួនសរុបនៃអ្នកផ្ទុកមេរោគអេដស៍ពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០២០*




## 4. ចំនួនសរុបនៃករណីស្លាប់ទាក់ទងនឹងមេរោគអេដស៍ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍

រូបភាពទី១១ បង្ហាញពីចំនួនសរុបនៃករណីស្លាប់ទាក់ទងនឹងមេរោគអេដស៍ក្នុងចំណោមកុមារ និងមនុស្សពេញវ័យ អាយុ>១៥ឆ្នាំ នៅទូទាំងប្រទេស។ ចំនួនករណីស្លាប់បានធ្លាក់ចុះសន្សឹមៗ ពីឆ្នាំ ២០១៦ រហូតដល់ឆ្នាំ២០២០ មានប្រមាណ ២ ០០០ ករណីក្នុងមួយឆ្នាំ។

រូបភាពទី ១១- ចំនួនសរុបនៃករណីស្លាប់ទាក់ទងនឹងមេរោគអេដស៍ និងក្រៅពីអេដស៍ ក្នុងចំណោមមនុស្សពេញវ័យដែលផ្ទុកមេរោគអេដស៍ ពីឆ្នាំ ២០១០-២០២០




# ការប៉ាន់ស្មាន និងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍ នៅថ្នាក់ក្រោមជាតិ

## 1. ចំនួនប្រជាជន នៅថ្នាក់ក្រោមជាតិ និង ផលធៀបតាមភេទ

តារាងទី១ ខាងក្រោមបង្ហាញពីចំនួនប្រជាជនតាមខេត្ត (ទាំងថ្មី និងចាស់) និងផលធៀបប្រុស និងស្រីដែលគេត្រូវការនៅក្នុងដំណើរការគណនាអាំងស៊ីដង់នៃមេរោគអេដស៍ក្នុងចំណោមស្រ្តីមានផ្ទៃពោះអាយុពី ១៥-២៤ ឆ្នាំ។ ថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាទើបតែបំបែកខេត្តថ្មីមួយ គឺខេត្តត្បូងឃ្មុំ ចេញពីខេត្តកំពង់ចាម ។ ដូច្នេះ ចំនួនប្រជាជននៅក្នុងខេត្តនេះ ត្រូវបានដកចេញពីមូលដ្ឋានទិន្នន័យឃុំឆ្នាំ ២០១៤ ដោយសារវាមិនខុសគ្នាពី CIP 2013 នោះទេ ហើយផលធៀបស្រីនិងប្រុស ត្រូវបានគណនាសម្រាប់ខេត្តនេះផងដែរ ដើម្បីយកមកប្រើប្រាស់នៅក្នុងជំហានបន្ទាប់ ក្នុងដំណើរការប៉ាន់ស្មាននៅថ្នាក់ខេត្ត។

**តារាងទី១** - *ចំនួនប្រជាជននៃប្រទេសកម្ពុជា យោងតាម CIP 2013*

| ល | ខេត្ត/ក្រុង | ប្រជាជនសរុប | ផលធៀបភេទF/M | # ប្រុស | % ប្រុស | # ស្រី | % ស្រី |
|---|---|---|---|---|---|---|---|
| 1 | បន្ទាយមានជ័យ | 729,624 | 94.60% | 354,689 | 4.98% | 374,935 | 4.96% |
| 2 | បាត់ដំបង | 1,121,001 | 98.80% | 557,117 | 7.83% | 563,884 | 7.46% |
| 3 | កំពង់ចាម | 1,007,277 | 90.90% | 479,631 | 6.74% | 527647 | 6.98% |
| 4 | កំពង់ស្ពឺ | 755,465 | 92.70% | 363,423 | 5.10% | 392042 | 5.19% |
| 5 | កំពង់ធំ | 690,386 | 93.70% | 333,966 | 4.69% | 356420 | 4.72% |
| 6 | កំពត | 611,583 | 98.70% | 303,791 | 4.27% | 307792 | 4.07% |
| 7 | កណ្ដាល | 1,115,959 | 93.10% | 538,041 | 7.56% | 577918 | 7.65% |
| 8 | កែប | 38,700 | 96.60% | 19,015 | 0.27% | 19685 | 0.26% |
| 9 | កំពង់ឆ្នាំង | 523,202 | 91.90% | 250,559 | 3.52% | 272643 | 3.61% |
| 10 | កោះកុង | 122,258 | 100.60% | 61,312 | 0.86% | 60946 | 0.81% |
| 11 | ក្រចេះ | 344,195 | 94.70% | 167,413 | 2.35% | 176782 | 2.34% |
| 12 | មណ្ឌលគិរី | 72,680 | 104.30% | 37,105 | 0.52% | 35575 | 0.47% |
| 13 | ឧត្ដរមានជ័យ | 231,387 | 100.70% | 116,097 | 1.63% | 115290 | 1.53% |
| 14 | ប៉ៃលិន | 65,795 | 99.80% | 32,865 | 0.46% | 32930 | 0.44% |
| 15 | ភ្នំពេញ | 1,688,040 | 93.60% | 816,119 | 11.46% | 871921 | 11.54% |
| 16 | ព្រះវិហារ | 235,355 | 98.40% | 116,728 | 1.64% | 118627 | 1.57% |
| 17 | ព្រៃវែង | 1,156,821 | 93.10% | 557,742 | 7.83% | 599079 | 7.93% |
| 18 | ពោធិ៍សាត់ | 435,562 | 91.60% | 208,233 | 2.92% | 227329 | 3.01% |
| 19 | រតនគិរី | 183,699 | 98.70% | 91,249 | 1.28% | 92450 | 1.22% |
| 20 | សៀមរាប | 922,975 | 93.90% | 446,969 | 6.28% | 476006 | 6.30% |
| 21 | ក្រុងព្រះសីហនុ | 250,180 | 96.70% | 122,991 | 1.73% | 127189 | 1.68% |
| 22 | ស្ទឹងត្រែង | 122,791 | 102.50% | 62,153 | 0.87% | 60638 | 0.80% |
| 23 | ស្វាយរៀង | 578,461 | 97.90% | 286,161 | 4.02% | 292300 | 3.87% |
| 24 | តាកែវ | 923,297 | 91.30% | 440,654 | 6.19% | 482644 | 6.39% |
| 25 | ត្បូងឃ្មុំ | 749,946 | 90.00% | 355,238 | 4.99% | 394708 | 5.22% |
| * | សរុប | **14,676,639** | | **7,119,261** | | **7,557,378** | |

## 2. ការប៉ាន់ស្មាន និងព្យាករណ៍ចំនួនអ្នកផ្ទុកមេរោគអេដស៍ នៅថ្នាក់ក្រោមជាតិ/ថ្នាក់ខេត្ត

តារាងទី ២ ខាងក្រោម បង្ហាញពីការប៉ាន់ស្មាន និងព្យាករណ៍ចំនួនសរុបនៃអ្នកផ្ទុកមេរោគអេដស៍នៅក្នុង ២៥ ខេត្ត ពីឆ្នាំ ២០១៥ ដល់ ២០២០។ ខេត្តនីមួយៗមានទំនោរធ្លាក់ចុះនៃចំនួនអ្នកផ្ទុកមេរោគ

អេដស៍ ប្រៀបធៀបរវាងឆ្នាំ ២០១៥ និង ២០២០ ។ ភ្នំពេញមានចំនួនអ្នកផ្ទុកមេរោគអេដស៍ច្រើនជាងគេបំផុតគឺ ប្រមាណ ១៤ ០០០ នាក់ក្នុងមួយឆ្នាំ។ ខេត្តផ្សេងទៀតដែលមានចំនួនអ្នកផ្ទុកមេរោគអេដស៍ច្រើនដែរ គឺ ខេត្តសៀមរាប និងបាត់ដំបង។ ខេត្តដែលមានចំនួនអ្នកផ្ទុកមេរោគអេដស៍តិចបំផុតគឺខេត្តកែប ដោយសារតែខេត្តនេះមានចំនួនប្រជាជនតិច។

តារាងទី ២ - ការប៉ាន់ស្មាន និងព្យាករណ៍ចំនួនសរុបនៃមនុស្សពេញវ័យដែលផ្ទុកមេរោគអេដស៍ [អាយុ>១៥ឆ្នាំ] នៅក្នុង ២៥ ខេត្ត

| Code | ABB | ខេត្ត | 2015 | 2016 | 2017 | 2018 | 2019 | 2020 |
|---|---|---|---|---|---|---|---|---|
| 01 | BMC | បន្ទាយមានជ័យ | 4,692 | 4,603 | 4,516 | 4,421 | 4,318 | 4,211 |
| 02 | BTB | បាត់ដំបង | 6,279 | 6,241 | 6,199 | 6,150 | 6,087 | 6,006 |
| 03 | KCM | កំពង់ចាម | 3,952 | 3,852 | 3,746 | 3,638 | 3,528 | 3,423 |
| 04 | KCN | កំពង់ឆ្នាំង | 1,259 | 1,211 | 1,163 | 1,118 | 1,076 | 1,036 |
| 05 | KDL | កណ្តាល | 4,226 | 4,074 | 3,932 | 3,794 | 3,663 | 3,539 |
| 06 | KEP | កែប | 48 | 49 | 49 | 50 | 50 | 51 |
| 07 | KKH | កោះកុង | 1,304 | 1,272 | 1,244 | 1,212 | 1,180 | 1,147 |
| 08 | KPT | កំពត | 1,597 | 1,592 | 1,582 | 1,568 | 1,552 | 1,532 |
| 09 | KSP | កំពង់ស្ពឺ | 2,610 | 2,545 | 2,475 | 2,402 | 2,329 | 2,257 |
| 10 | KTE | ក្រចេះ | 762 | 738 | 711 | 686 | 660 | 636 |
| 11 | KTM | កំពង់ធំ | 1,957 | 1,872 | 1,790 | 1,709 | 1,636 | 1,570 |
| 12 | MDK | មណ្ឌលគិរី | 117 | 103 | 91 | 82 | 75 | 68 |
| 13 | OMC | ឧត្តរមានជ័យ | 1,027 | 953 | 887 | 828 | 778 | 735 |
| 14 | PLN | ប៉ៃលិន | 416 | 416 | 416 | 414 | 413 | 411 |
| 15 | PNH | ភ្នំពេញ | 14,779 | 14,629 | 14,467 | 14,312 | 14,145 | 13,953 |
| 16 | PST | ពោធិ៍សាត់ | 2,068 | 1,996 | 1,927 | 1,858 | 1,790 | 1,724 |
| 17 | PVG | ព្រៃវែង | 3,588 | 3,483 | 3,382 | 3,280 | 3,180 | 3,084 |
| 18 | PVH | ព្រះវិហារ | 293 | 294 | 296 | 298 | 298 | 298 |
